ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែមិថុនា ឆ្នាំ២០២៤

នៅក្នុងខែមិថុនា ឆ្នាំ២០២៤ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា

#### ១.១.១-បដិសណ្ឋារកិច្ចឡើងជាតិ-អន្តរជាតិ

- បានអនុញ្ញាតឱ្យលោកជំទាវអ្នកឧកញ៉ា **ម៉ៅ ចំណាន** និងគណៈប្រតិភូសមាគមសិល្បករខ្មែរ ចូលជួបសម្តែងគារវកិច្ច នៅវិមាន៧មករា។
- បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិជួបពិភាក្សាការងារតាមប្រព័ន្ធនិម្មិត និងចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងជម្រាបលា ចំនួន១៣លើក រួមមាន៖
  - ជំនួបពិភាក្សាការងារជាមួយឯកឧត្តម **ឡូយ ជេម អូស្ទីន** III (Lloyd James Austin III) រដ្ឋមន្ត្រីការពារជាតិសហរដ្ឋអាមេរិក នាឱកាសដែលឯកឧត្តមអញ្ជើញមកធ្វើទស្សនកិច្ច នៅកម្ពុជា ជាលើកទី២ នៅវិមានព្រឹទ្ធសភា។
  - ជំនួបសម្តែងការគួរសមដោយ ឯកឧត្តម **ម៉ារីស សាងៀមផុង្សា** (Maris Sangiampongsa) រដ្ឋមន្ត្រីការបរទេសនៃព្រះរាជាណាចក្រថៃ ក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា។
  - ជំនួបពិភាក្សាការងារជាមួយឯកឧត្តម **វីលៀម ជេ ប៊ឺនស** (William J. Burns) នាយកទីភ្នាក់ងារស៊ើបការណ៍មជ្ឈិម (CIA) របស់សហរដ្ឋអាមេរិក នៅនិវេសនដ្ឋាន **សម្តេចតេជោ** ក្រុងតាខ្មៅ ខេត្តកណ្តាល។
  - ជំនួបពិភាក្សាការងារជាមួយឯកឧត្តម **រូស្លាន ស្តេហ្វានឈុក** (Ruslan Stefanchuk) ប្រធានសភាអ៊ុយក្រែនតាមប្រព័ន្ធនិម្មិតនៅភូមិគ្រឹះសម្តេចតេជោក្រុងតាខ្មៅ ខេត្តកណ្តាល។



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (855 23) 211 441, 211 442, 211 443 ទូរសារ៖ (855 23) 211 446, E-mail: secretariat@senate.gov.kh

- ជំនួបសម្តែងការគួរសមដោយ ឯកអគ្គរដ្ឋទូត និងរាជទូតវិសាមញ្ញ និងពេញសមត្ថភាពប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាន នៅរាជធានីភ្នំពេញ ចំនួន៨រូប នៅវិមានព្រឹទ្ធសភា រួមមាន៖
  - ឯកឧត្តម **វ៉ាង វិនធៀន** (Wang Wentian) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន នាឱកាសដែលឯកឧត្តមចប់បេសកកម្ម និងជម្រាបលា។
  - ឯកឧត្តម **ដូមីនីក វីលៀមស៍** (Dominic Williams) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃចក្រភពអង់គ្លេស។
  - លោកជំទាវ **មីឡេនណា ការីដាដ ហ្សាឌីវ៉ា ពាជ្រា** (Milena Caridad Zaldivar Piedra) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋគុយបា នាឱកាសដែលលោកជំទាវ ទើបតែចាប់ផ្តើមបេសកកម្មការទូតនៅកម្ពុជា។
  - ឯកឧត្តម **សាន់តូ ដាម៉ូស៊ូម៉ាតូ** (Santo Darmosumarto) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋឥណ្ឌូណេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្តម **ផាក ជុងវុក** (Park Jung-Wook) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្តម **អាណាតូលី បូរ៉ូវិក** (Anatoly Borovik) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
  - ឯកឧត្តម **អ៊ីហ្គោរ៍ ទ្រីសម៉ាន់** (Igor Driesmans) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសហភាពអឺរ៉ុប។
  - ឯកឧត្តម **ស្សាហារូឌីន ប៊ីន អ៊ិន** (Shaharuddin Bin Onn) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃប្រទេសម៉ាឡេស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា។
- ជំនួបសម្តែងការគួរសម ដោយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមាននិវេសនដ្ឋាននៅក្រៅប្រទេសចំនួន១រូប នៅវិមានព្រឹទ្ធសភា គឺឯកឧត្តម **ម៉ូហាមេដ អាប់ឌុល ហៃ** (Mohammed Abdul Hye) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ប្រចាំព្រះរាជាណាចក្រកម្ពុជា។

## ១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមជាគណៈអធិបតី និងដង្ហែព្រះរាជដំណើរ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីថ្វាយព្រះភ្លើង **ព្រះបរមសពសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះមេរុវត្តបទុមវតី។
- បានអញ្ជើញចូលក្រាបបង្គំគាល់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង និង

- បានអញ្ជើញប្រគេនចង្ហាន់ និងទេយ្យវត្ថុ ថ្វាយ**សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត** សម្តេចព្រះសង្ឃរាជស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តបទុមវតីរាជវរារាម។

**១.១.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន៣០ច្បាប់ និងជ្រាបជាព័ត៌មាន ចំនួន៥១ច្បាប់។

## ១.២-ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា

### ១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញជាអធិបតីដឹកនាំប្រជុំក្រុមសមាជិកព្រឹទ្ធសភាភូមិភាគទី១ រាជធានីភ្នំពេញ ដើម្បីពិនិត្យ និងសម្រេចការងារមួយចំនួនរបស់ក្រុមសមាជិកព្រឹទ្ធសភាភូមិភាគទី១ នៅវិមានព្រឹទ្ធសភា និង
- បានអញ្ជើញជាអធិបតីដឹកនាំប្រជុំ ដើម្បីត្រៀមលក្ខណៈសម្រាប់ចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង(APF) នៅទីក្រុង Montréal ប្រទេសកាណាដា ចំនួន២លើក នៅវិមានព្រឹទ្ធសភា។

### ១.២.២-សកម្មភាពចុះមូលដ្ឋាន

- បានអញ្ជើញនាំយកទេយ្យទាន និងបច្ច័យប្រគេនព្រះសង្ឃ និងតាជីយាយជីចាស់ជរា នៅក្នុងវត្តជ្រោយឧត្តម នៅភូមិព្រៃឈ្មោះ ឃុំព្រែកតាសរ ស្រុកពោធិ៍រៀង ខេត្តព្រៃវែង។

### ១.២.៣-បដិសណ្ឋារកិច្ចឡៀវជាតិ-អន្តរជាតិ

- បានអញ្ជើញចូលរួមក្នុងកិច្ចជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម **ឡូយ ជេម អូស្ទីន** III (Lloyd James Austin III) រដ្ឋមន្ត្រីការពារជាតិអាមេរិក នៅវិមានព្រឹទ្ធសភា។
- បានអនុញ្ញាតឱ្យលោកជំទាវ **មីឡេនណា ការីដាដ ហ្សាឌីវ៉ា ពាដ្រា** (Milena Caridad Zaldivar Piedra) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តម និង
- បានអនុញ្ញាតឱ្យលោកជំទាវ Tiffany McDonald ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំអាស៊ាន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ទទួលភ្ញៀវរបស់ឯកឧត្តម។

### ១.២.៤-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើង ព្រះបរមសពសម្តេចព្រះអគ្គមហាសង្ឃ**រាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម**

**សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះមេរុវត្តបទុមវតី។

- បានអញ្ជើញជាអធិបតីបិទសិក្ខាសាលាស្តីពី "កម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល" នៅសណ្ឋាគារសុខាភ្នំពេញ។
- បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្ទេរ និងចូលកាន់តំណែងអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ និងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៤ នៅសាលបណ្ណាល័យព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីអបអរសាទរខួបគម្រប់១០ឆ្នាំ របស់បណ្ឌិត្យសភាបច្ចេកវិទ្យា ឌីជីថលកម្ពុជា (CADT) នៅមជ្ឈមណ្ឌលបណ្ឌិត្យសភាបច្ចេកវិទ្យា ឌីជីថលកម្ពុជា។
- បានអញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសពលោក **ងិន ជីវ៉ូ** ចៅសង្កាត់ព្រែកប្រា នៅខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ត្រូវជាម្តាយក្មេកឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតនៅសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

### ១.២.៥-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន ៩៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៣២ច្បាប់។

## ១.៣-ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា

### ១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

- បានអញ្ជើញដឹកនាំកិច្ចប្រជុំការងារស្តីពី ការចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ សម្រាប់នីតិកាលទី៥ នៅបន្ទប់ប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២។
- បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រតិភូ ដើម្បីត្រៀមចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង(APF) នៅទីក្រុង Montréal នៅប្រទេសកាណាដា នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីត្រៀមលក្ខណៈចូលរួមជាមួយរដ្ឋសភាកម្ពុជានៅក្នុងការរៀបចំសម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាពេលខាងមុខនេះ នៅវិមានព្រឹទ្ធសភា និង
- បានអញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រុមទីប្រឹក្សាឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា នៅបន្ទប់ប្រជុំខុទ្ទកាល័យអនុប្រធានទី២។

### ១.៣.២-បដិសណ្ឋារកិច្ចឡៃវជាតិ-អន្តរជាតិ

- បានអញ្ជើញចូលរួមអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភាទទួលជួបសន្ទនាការងារជាមួយឯកឧត្តម **រូស្លាន ស្តេហ្វានឈុក** (Ruslan Stefanchuk) ប្រធានសភាអ៊ុយក្រែន តាមប្រព័ន្ធនិម្មិត នៅភូមិគ្រឹះសម្តេចតេជោ ក្រុងតាខ្មៅ។
- បានអញ្ជើញចូលរួមក្នុងកិច្ចជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជាមួយឯកឧត្តម **ឡយ ជេម អូស្ទីន III** (Lloyd James Austin III) រដ្ឋមន្ត្រីការពារជាតិអាមេរិក នៅវិមានព្រឹទ្ធសភា។
- បានអនុញ្ញាតឱ្យលោក Kim Jung Nam ប្រធានមូលនិធិ Global Life Sharing ចូលជួបសម្តែងការគួរសម និងបន្តពិធីចុះហត្ថលេខាលើអនុស្សរណៈ (MOU) រវាងព្រឹទ្ធសភាជាមួយប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល Global Life Sharing នៃសាធារណរដ្ឋកូរ៉េ នៅវិមានព្រឹទ្ធសភា។
- បានរៀបចំពិធីពិសាអាហារពេលល្ងាចជូន**ឯកឧត្តម វ៉ាង វិនធៀន** (WANG Wentian) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសដែលឯកឧត្តមឯកអគ្គរដ្ឋទូតនឹងត្រូវបញ្ចប់អាណត្តិបេសកកម្មការទូត នៅភោជនីយដ្ឋាន Topaz រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីជប់លៀងក្នុងឱកាសបុណ្យជាតិរបស់សហព័ន្ធរុស្ស៊ី នៅសណ្ឋាគារ Sofitel Phnom Penh Phokeethra និង
- បានអញ្ជើញចូលរួមជាកិត្តិយសពិសាអាហារមិត្តភាពជាមួយលោកស្រី Bec Strating សាស្ត្រាចារ្យ មកពីនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃសាកលវិទ្យាល័យ La Trobe និងអ្នកសម្រួលផ្លូវសមុទ្រសម្រាប់កិច្ចប្រជុំកំពូល អូស្ត្រាលី អាស៊ាន នៅភោជនីយដ្ឋានក្រវ៉ាញ រាជធានីភ្នំពេញ។

### ១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើង **ព្រះបរមសពសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះមេរុវត្តបទុមវតី។
- បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារសិក្សាចំនួន ២ខ្នង ស្មើនឹង១២បន្ទប់ នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម។
- បានអញ្ជើញចូលរួមក្នុងពិធីប្រកាសផ្ទេរ និងចូលកាន់តំណែងអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកពិធីការ និងទំនាក់ទំនងអន្តរជាតិ និងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែឧសភា ទិសដៅការងារខែមិថុនា ឆ្នាំ២០២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅសាល

បណ្ណាល័យព្រឹទ្ធសភា និង

- បានអញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ត្រូវជាម្តាយក្មេកឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

### ១.៣.៤-ពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗ ចំនួន ២៣ច្បាប់។

## ២-គណៈកម្មការនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភាបានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១-មុខងារតំណាង

- បានទទួលពាក្យបណ្តឹង ចំនួន៥បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន៥បណ្តឹង បានទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន ២បណ្តឹង។
- បានយាង និងអញ្ជើញចូលរួមក្នុងពិធីខួបគម្រប់២០ឆ្នាំរបស់អង្គការមូលនិធិកុមារកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅរាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីថ្វាយព្រះពរជ័យសិរីមង្គល ក្នុងឱកាសចម្រើនព្រះជន្មវស្សានមង្គលគម្រប់៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅព្រះបរមរាជវាំង។
- បានយាងដង្ហែព្រះករុណាជាអម្ចាស់ជីវិតលើត្បូង**ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ព្រះអង្គទាំងទ្វេសព្វព្រះរាជហឫទ័យព្រះបរមរាជានុញ្ញាតព្រះរាជទាន ព្រះតេជព្រះគុណបណ្ឌិត KORI Shinkai នាយកប្រតិបត្តិនៃនិកាយ Nenbutsushu វត្ត Sampozan Muryojuji ព្រមទាំងគណៈប្រតិភូចូលក្រាបថ្វាយបង្គំគាល់ ថ្វាយព្រះគោរមងារព្រះករុណាព្រះមហាក្សត្រ និងថ្វាយព្រះសព្ទសាធុការពរ ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមវិសេសវិសាល នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មគម្រប់៨៨ព្រះវស្សា យាងចូល ៨៩ព្រះវស្សា នៃសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះរាជដំណាក់សិរីមង្គល ក្នុងព្រះបរមរាជវាំង។
- បានយាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់របស់**ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ចូលរួមក្នុងពិធីមហា

សន្និបាតលើកទី១១ សមាគមដូនជី និងឧបាសិកាកម្ពុជារង្វេ នៅមណ្ឌលបណ្តុះបណ្តាលពុទ្ធសាសនិកនារី អតីតវត្តលោកកោះ ស្រុកពញាឮ ខេត្តកណ្តាល។

- សព្វព្រះហឫទ័យយកអំណោយដ៏ថ្លៃថ្លាជាជំនួយរបស់ក្រុមហ៊ុន **ម៉ៅ ថាយ** ចែកជូនដល់ក្រុមគ្រួសារអ្នកជំងឺដែលមានជីវភាពខ្វះខាតកំពុងសម្រាកព្យាបាល ព្រមទាំងបុគ្គលិក មន្ត្រីបម្រើការ នៅមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ ចំនួន ១៥០នាក់។
- បានអញ្ជើញចូលថ្វាយបង្គំ**សម្តេចព្រះពោធិវង្សកិត្តិបណ្ឌិត អ៊ំ លឹមហេង** សម្តេចព្រះសង្ឃនាយកស្តីទី គណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា នៅវត្តមុនីសុវណ្ណ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន៩លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមានៈ ពិធីសម្ពោធបើកឱ្យដំណើរការជាផ្លូវការកំពង់ផែពហុបំណងកំពត របស់ក្រុមហ៊ុនកំពតផត, ពិធី " អ្នកស្នងមរតក " រក្សាចាស់ បង្កើត និងអភិវឌ្ឍន៍ថ្មី, ពិធីបើកការដ្ឋានសាងសង់ស្ពានអាកាសភ្លោះ ត្រង់ចំណុចប្រសព្វមហាវិថី **សម្តេចតេជោ ហ៊ុន សែន** និងផ្លូវជាតិលេខ២, ពិធីសម្ពោធមជ្ឈមណ្ឌលវប្បធម៌ព្រះពុទ្ធសាសនា ព្រះធម្មចេតិយ តម្កល់ព្រះត្រៃបិដកចម្លាក់ថ្មម៉ាប ១១៧០ផ្ទាំង ផ្លូវបេតុង ៩ខ្សែ បូជនីយដ្ឋានសមថៈវិបស្សនា និងសមិទ្ធិផលនានា, ពិធីបុណ្យទីឃាយុវឌ្ឍនមង្គល ប្រោះព្រំព្រះសុគន្ធវារីថ្វាយ **សម្តេចព្រះមហាសុមេធាធិបតីកិត្តិឧទ្ទេសបណ្ឌិត នន្ទ ង៉ែត** សម្តេចព្រះមហាសង្ឃរាជស្តីទី នៃព្រះរាជាណាចក្រកម្ពុជា គម្រប់ព្រះជន្ម ១០០ព្រះវស្សា យាងចូល ១០១ព្រះវស្សា នៅរាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ និងខេត្តកំពត។
- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីថ្វាយព្រះភ្លើងព្រះបរមសព **សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត ទេព វង្ស** សម្តេចព្រះមហាសង្ឃរាជ នៃព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះមេរុវត្តបទុមវតី។
- បានអញ្ជើញចូលរួមពិធីបុណ្យខួបគម្រប់៩ឆ្នាំ និងគម្រប់១៥ឆ្នាំ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម** នៅវត្តមុនីប្រសិទ្ធីវង្ស ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួប១០ឆ្នាំរបស់បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា នៅបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី " កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជូនតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា " នៅសណ្ឋាគារសុខាភ្នំពេញ រាជធានីភ្នំពេញ។

- អញ្ជើញចូលរួមស្តាប់ការធ្វើបទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើសេចក្តីព្រាងច្បាប់ស្តីពី ការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងបញ្ហាផ្សេងៗ នៅសាលប្រជុំគណៈកម្មការទី៩ ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ដើម្បីពិនិត្យ និងពិភាក្សាលើការងារសំខាន់ៗរួមមាន៖ សេចក្តីព្រាងផែនការយុទ្ធសាស្ត្ររបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ) នីតិកាលទី៥ រយៈពេល៦ឆ្នាំ(២០២៤-២០៣០) សេចក្តីព្រាងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ របស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ និងការងារផ្សេងៗ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី២ព្រឹទ្ធសភា នៅបន្ទប់ប្រជុំខុទ្ទកាល័យអនុប្រធានទី២ព្រឹទ្ធសភា។
- បានយាង និងអញ្ជើញចូលរួមប្រជុំជាមួយក្រុមសមាជិកាព្រឹទ្ធសភាស្តីពី ការពិនិត្យឆ្លងសេចក្តីសម្រេច តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ក្រុមសមាជិកាព្រឹទ្ធសភា ពិភាក្សាសេចក្តីព្រាងផែនការសកម្មភាពក្រុមសមាជិកាព្រឹទ្ធសភារយៈពេល៦ឆ្នាំ នីតិកាលទី៥ (២០២៤-២០៣០) និងពិនិត្យពិភាក្សាសេចក្តីព្រាងផែនការសកម្មភាពការងាររបស់ក្រុមសមាជិកាព្រឹទ្ធសភាប្រចាំឆ្នាំ២០២៤ ក្រោមអធិបតីភាពលោកជំទាវ **មាន សំអាន** ប្រធានក្រុមសមាជិកា នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ដើម្បីពិនិត្យ និងផ្តល់យោបល់លើផែនការយុទ្ធសាស្ត្រ៦ឆ្នាំ (ឆ្នាំ២០២៤-២០៣០) ផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៤ និងបញ្ហាផ្សេងៗ ក្រោមអធិបតីភាពឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅបន្ទប់ប្រជុំគណៈកម្មការទី៤ព្រឹទ្ធសភា។
- បានអញ្ជើញទទួលជួបជាមួយប្រជាកសិករដាំដំណាំត្រសក់ផ្អែម មកពីស្រុកសំឡូត ខេត្តបាត់ដំបង ដើម្បីផ្លាស់ប្តូរបទពិសោធន៍ និងសិក្សាលើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ព្រមទាំងទស្សនកិច្ចនៅតំបន់អភិវឌ្ឍន៍កសិទេសចរណ៍ **ម៉ុង ឫទ្ធី** សែនជ័យ។
- បានអញ្ជើញចូលរួមដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ ចំពោះវីរយុទ្ធជន វីរយុទ្ធនារី និងប្រជាជនកម្ពុជា ពលីក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅមហាចេតិយតំបន់ប្រវត្តិសាស្ត្រយោធាតេជោកោះថ្មX16 ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ក្នុងឱកាសរំលឹកខួបលើកទី៤៧ នៃទិវាចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ២០ មិថុនា ១៩៧៧ - ២០ មិថុនា ២០២៤។
- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ **ឯម ជា** ម្តាយក្មេកឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ ព្រឹទ្ធសភា នៅគេហដ្ឋាន ស្ថិតក្នុងសង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ និង
- សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជនយុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់

លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានី និងតាមបណ្តាខេត្ត ក្រុងនានា ចំនួន៩៩លើក ព្រមទាំង បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន១៣២លើក។

## ២.២-កិច្ចសហប្រតិបត្តិការអន្តរជាតិ

សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្មក្នុងការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេសទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

- ឯកឧត្តម **ជី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំត្រៀមសម្រាប់សម័យប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) នៅវិមានរដ្ឋសភា។
- ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បាន៖
    - អញ្ជើញទៅចូលរួមវេទិកាក្រោមមូលបទ "ភាពជាដៃគូតំបន់ដើម្បីការអភិវឌ្ឍរួម (Regional Partnership for Common Development)" នៅទីក្រុង Huangshan ខេត្ត Anhui នៃសាធារណរដ្ឋប្រជាមានិតចិន និង
    - អនុញ្ញាតឱ្យថ្នាក់ដឹកនាំសាកលវិទ្យាល័យអន្តរជាតិផារ៉ាហ្គន (PARAGON International University) ដឹកនាំដោយលោក **ដាមៀរ មូរសែវ (Mr. Damir Musaev)** នាយកប្រតិបត្តិក្រុមហ៊ុនផារ៉ាហ្គន អញ្ជើញចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។
- ឯកឧត្តមបណ្ឌិត **ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បាន៖
    - អញ្ជើញចូលរួមពិធីបើកសម្ពោធការិយាល័យអគ្គកុងស៊ុលអាល្លឺម៉ង់ និងចូលរួមពិធី Cocktail Reception តាមការអញ្ជើញរបស់លោក **Stefan Messerer** ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅភោជនីយដ្ឋានស្លាបព្រា នៅខេត្តសៀមរាប។
    - អញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ និងពិភាក្សាការងារជាមួយលោក **UENO Atsushi** ឯកអគ្គរាជទូតជប៉ុន នៅនិវេសនដ្ឋានឯកអគ្គរាជទូតជប៉ុន នៅបរិវេណស្ថានទូតជប៉ុន រាជធានីភ្នំពេញ។
    - អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្មស្តេច **Charles III** នៃចក្រភពអង់គ្លេស នៅសណ្ឋាគារ Himawari រាជធានីភ្នំពេញ។
    - អញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ និងពិភាក្សាការងារជាមួយ **Mr. Pablo Kang,** Chargé d'affaires of Australia និងសាស្ត្រាចារ្យ **Professor Bec Strating,** International Relations Department នៅភោជនីយដ្ឋានក្រវាញ រាជធានីភ្នំពេញ និង

- អញ្ជើញចូលរួមពិសាអាហារថ្ងៃត្រង់ និងពិភាក្សាការងារជាមួយលោកជំទាវ Ülkü Kocafe ឯកអគ្គរដ្ឋទូតតួកគី និង Ms. Pınar Numanoğlu នៅភោជនីយដ្ឋាន Le deli bistro gourmet រាជធានីភ្នំពេញ។

- ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំតំបន់អាស៊ី-ប៉ាស៊ីហ្វិកសភាប្រើភាសាបារាំង (APF) (Assemblée Parlementaire de la Francophonie) តាមរយៈប្រព័ន្ធនិម្មិត នៅវិមានព្រឹទ្ធសភា និង
  - អញ្ជើញចូលរួមកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈសម្រាប់ការចូលរួមមហាសន្និបាតលើកទី៤៩ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុង Montréal ប្រទេសកាណាដា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា និងជាប្រធានគណៈប្រតិភូសភាកម្ពុជា នៅវិមានព្រឹទ្ធសភា។
- ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលបដិសណ្ឋារកិច្ចស្វាគមន៍ គណៈប្រតិភូកូរ៉េ ដឹកនាំដោយលោក Kim Jung-Nam ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ មកទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

ថ្ងៃអង្គារ ១១កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី១**

**ប្រាក់ សុខុន**

*ចម្លងជូន*

- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន (ជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*